ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
05 / 09 / 2012
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ២៣ ខែ សីហា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ១០១

រៀបចំដោយ: សែ គុលវុឌ្ឍី និង Matteo CRIPPA

| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធួ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោកស្រី សែ គុលវុឌ្ឍី, លោក Matteo CRIPPA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក វេង ហ៊ត់, លោក ចាន់ ដារារស្មី, លោក Vincent de Wilde d'Estmael, លោក RAYNOR Keith, |
| ជនជាប់ចោទ៖ អៀង សារី (ពីបន្ទប់ឃុំខ្លួនខាងក្រោម), នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Jasper PAUW, លោក សុន អារុណ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KANAVAS |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោកស្រី Christine MARTINEAU, លោក គីម ម៉េងឃី, លោក វ៉ែន ពៅ, លោកស្រី Beini YE |
| សាក្សី៖ គីម វុន ហៅណោម (TCW-338), អ៊ែម អឿន (TCCP-28) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ កញ្ញា Eleanor DOYLE-MARKWICK |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.១០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.២៥ | បញ្ចប់ម៉ោង៖ ១០.៤៥ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៥ ម៉ោង | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ០៩.០៤<br>១២.០១ | ០៩.០៧<br>១២.០២ |
| ការបន្តតាំងសំណួរទៅកាន់សាក្សី គីម វុន ហៅណោម (TCW-338) | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី អៀង សារី | ០៩.០៨<br>១១.០៩ | ១១.០៩<br>១១.៣១ |
| ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ែម អឿន (TCCP-28) | អង្គជំនុំជម្រះ<br>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ១១.៣៦<br>១១.៤៤ | ១១.៤៣<br>១៦.១០ |
| ការតាំងសំណួរដោយតំណាងភាគីនីមួយៗ | អង្គជំនុំជម្រះ | ១៣.៣០ | ១៣.៣៥ |
| កិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ | អង្គជំនុំជម្រះ | ១៦.០៩ | ១៦.១០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ (ជនជាប់ចោទ អៀង សារី សម្រាប់រយៈពេលពេញមួយថ្ងៃ ហើយជនជាប់ចោទ នួន ជា សម្រាប់រយៈពេលមួយរសៀល) ។

**ការតាំងសំណួរទៅកាន់សាក្សី គីម វុន ហៅអោម** (TCW-338)

មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី អៀង សារី បានតាំងសំណួរទៅសាក្សី។ សក្ខីកម្មរបស់សាក្សី គីម វុន ហៅអោម បានបញ្ចប់នៅក្នុងថ្ងៃដដែលនេះ។

**ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន** (TCCP-28)

ប្រធានអង្គជំនុំជម្រះបានតាំងសំណួរអំពីប្រវត្តិសាវតារបស់ដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់មកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយមេធាវីតំណាងនៃភាគីនីមួយៗ**

អង្គជំនុំជម្រះបានរំលឹកដល់ភាគីទាំងអស់អំពីសំណើសុំដែលបានស្នើឡើងក្នុងអំឡុងពេលកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ឲ្យក្រុមនីមួយៗរៀបចំ ប្រសិនបើអាចឲ្យមានមេធាវីតំណាងនៃក្រុមក្នុងការតាំងសំណួរជំនួសឲ្យក្រុមរបស់ខ្លួន។

**កិច្ចប្រជុំរៀបចំសវនាការថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២**

អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីថា អង្គជំនុំជម្រះនឹងរៀបចំកិច្ចប្រជុំរៀបចំសវនាការបន្តទៀតនៅរសៀលថ្ងៃចន្ទ ទី ២៧ ខែ សីហា ឆ្នាំ ២០១២ ដោយសារតែកិច្ចប្រជុំរៀបចំសវនាការដែលបានធ្វើកាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ មិនទាន់បានពិភាក្សាចប់របៀបវារៈដែលអង្គជំនុំជម្រះបានគ្រោងទុកនោះ។ ហើយកិច្ចប្រជុំនេះនឹងធ្វើឡើងជាអសាធារណៈ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/380 | D201/<br>10 | 00357195-<br>00357202<br>00365640-<br>00365647<br>00485428-<br>00485434 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី KIM Vun គីម វុន ចុះថ្ងៃទី 25-07-2009<br>[Surrogate Sheet] Written Record of Interview of KIM Vun គីម វុន dated 25 July 2009<br>[Feuille remplacée] Procès verbal d'audition de témoin KIM Vun គីម វុន en date du 25 Juillet 2009 | P | | | |
| E3/381 | D201/<br>11 | 00357203-<br>00357207<br>00365526-<br>00365530<br>00402996-<br>00403000 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី KIM Vun គីម វុន ចុះថ្ងៃទី 28-07-2009<br>[Surrogate Sheet] Written Record of Interview of KIM Vun គីម វុន dated 28 July 2009<br>[Feuille remplacée] Procès verbal d'audition de témoin KIM Vun គីម វុន en date du 28 Juillet 2009 | P | 00357203,<br>00357205,<br>00357206-<br>07 | 00365526,<br>00365528,<br>00365229 | 00402996,<br>00402998-<br>999 |
| N/A | D243/<br>4 | 00439917-<br>00439923<br>00429019-<br>00429022<br>00485278-<br>00485281 | ដីកាសម្រេចលើសំណើររបស់សហព្រះរាជអាជ្ញាដើម្បីដាក់ទស្សនាវដ្តី "ទង់បដិវត្តន៍" ចំនួន ១៩ច្បាប់ និង "យុវជននិងយុវនារីបដិវត្តន៍" ចំនួន១៨ច្បាប់ និង សំណើសុំកិច្ចស៊ើបសួរដោយសហព្រះរាជអាជ្ញាទាក់ទងនឹង ទស្សនាវដ្តីប.ក.ក "ទង់បដិវត្តន៍" និង "យុវជននិងយុវនារីបដិវត្តន៍"<br>Order on Co-Prosecutors'Request for admission of 19 issues of "Revolutionnary Flag"and 18 issues of "Revolutionary Youth" and Co-Prosecutors' Request For Investigative Action Regarding CPK Magazines Revolutionary Flag And Revolutionary Youth<br>Ordonnance sur la Demande des co-procureurs d'admettre 19 séries de "Drapeau révolutionnaire" et 18 séries de "Jeunnesse révolutionnaire" et la Demande des co-procureurs d'actes d'instruction concernant les magazines du PCK "Drapeau révolutionnaire" et "Jeunnesse révolutionnaire" | P | | | |
| E3/1729 | D22/3<br>963 | 00573967-<br>00573988<br>00751861-<br>00751874<br>00786171-<br>00786194 | ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អែម អឿន EM Oeun 10-VU-00964<br>Civil party application of EM Oeun 10-VU-00964<br>Demande de constitution de partie civile de EM Oeun 10-VU-00964 | P | 00573979 | 00751867 | 00786186 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (០៩.០៨) និង នួន ជា (១២.០៥) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួន (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ នាំសាក្សី គីម វុន ហៅឆោម (TCW-338) ត្រឡប់ទៅកាន់គេហដ្ឋាន របស់គាត់វិញ។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ នាំដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន (TCCP-28) ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងបង្គាប់ឱ្យនាំត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១២ ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ ចន្ទ ទី ២៧ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២

ក្រឡាបញ្ជី ... ក្រឡាបញ្ជី

សែ គុល[illegible] Matteo CRIPPA